**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តតាកែវ**

លេខៈ...០៣៧...ស.ស.ទ

តាកែវ ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ២០១៧

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតក្រុមការងារចុះពិនិត្យ ទប់ស្កាត់ និងវាយតម្លៃលក្ខណៈបច្ចេកទេសសុវត្ថិភាព ក្នុងការគ្រប់គ្រងបណ្តាស្ថានីយប្រេង និងឧស្ម័នឥន្ធនៈក្នុងខេត្ត

## អភិបាលខេត្តតាកែវ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /០៣១៤/២៩៨ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៤ ស្តីពីការតែងតាំងអភិបាល នៃគណៈអភិបាលខេត្តតាកែវ
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បកចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង ក្រុមប្រឹក្សា គណៈអភិបាលស្រុក និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌ
- ប្រកាសលេខ ១០៥ រថ.បវប.ប្រក ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៦ របស់ក្រសួងរ៉ែ និងថាមពល ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ
- ប្រកាសលេខ ១០៦ រថ.បវប.ប្រក ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៦ របស់ក្រសួងរ៉ែ និងថាមពល ស្តីពីការកែសម្រួលប្រការ ៨, ១១, ១២, ១៥ និង ១៧ នៃប្រកាសលេខ ០០៩២ រថ.បវប.ប្រក ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៥ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ
- សារាចរលេខ ០៣២៩.រថ.បវប.សរច ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ របស់ក្រសួងរ៉ែ និងថាមពល ស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ
- លិខិតលេខ ០៥១៧ រថ.នក.លស ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៧ របស់ក្រសួងរ៉ែ និងថាមពល ស្តីពីសំណើសុំកិច្ចសហការក្នុងការចុះពិនិត្យ ទប់ស្កាត់ និងវាយតម្លៃលក្ខណៈបច្ចេកទេសសុវត្ថិភាព ក្នុងការគ្រប់គ្រងបណ្តាស្ថានីយប្រេង និងឧស្ម័នឥន្ធនៈ នៅទូទាំងប្រទេសកម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់រដ្ឋបាលខេត្តតាកែវ

## សម្រេច

**ប្រការ ១.**

ត្រូវបានបង្កើតក្រុមការងារចុះពិនិត្យ ទប់ស្កាត់ និងវាយតម្លៃលក្ខណៈបច្ចេកទេសសុវត្ថិភាពក្នុងការគ្រប់គ្រងបណ្តាស្ថានីយប្រេង និងឧស្ម័នឥន្ធនៈក្នុងខេត្ត ដែលមានសមាសភាពដូចខាងក្រោម៖

| | | | | | |
|---|---|---|---|---|---|
| ១- | លោក | **ខាន់** | **សុខា** | អភិបាលរងខេត្ត | ប្រធាន |
| ២- | លោក | **ម៉ឺង** | **ឧុធី** | នាយករដ្ឋបាលសាលាខេត្ត | អនុប្រធាន |
| ៣- | លោក | **ផេង** | **ឧុធ** | ប្រធានមន្ទីររ៉ែ និងថាមពលខេត្ត | អនុប្រធានអចិន្ត្រៃយ៍ |
| ៤- | លោកវរៈសេនីយឯក | **ជា** | **សំអាត** | មេបញ្ជាការរងកងរាជអាវុធហត្ថខេត្ត | សមាជិក |
| ៥- | លោកវរៈសេនីយត្រី | **ហ៊ុន** | **ហៃម** | នាយការិយាល័យបង្កា និងពន្លត់អគ្គិភ័យ នៃស្នងការដ្ឋាននគរបាលខេត្ត | សមាជិក |
| ៦- | លោកអភិបាលក្រុង-ស្រុកគ្រប់ស្រុក | | | | សមាជិក |
| ៧- | លោក | **នួន** | **សុធា** | អនុប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត | សមាជិក |
| ៨- | លោក | **ហុង** | **ភារៈ** | អនុប្រធានមន្ទីរបរិស្ថានខេត្ត | សមាជិក |
| ៩- | កញ្ញា | **ម៉ន** | **វតនា** | នាយកស្តីទី ទីចាត់ការអន្តរវិស័យសាលាខេត្ត | សមាជិក |
| ១០- | លោក | **ធិត** | **ពៅ** | អនុប្រធានមន្ទីររ៉ែ និងថាមពលខេត្ត | សមាជិក |
| ១១- | លោក | **អន** | **ដាវន្នី** | ប្រធានការិយាល័យគ្រប់គ្រងការអភិវឌ្ឍ និង សំណង់សាលាខេត្ត | សមាជិក |
| ១២- | លោក | **ម៉ម** | **ផន** | ប្រធានការិយាល័យថាមពល និងប្រេងកាត នៃមន្ទីររ៉ែ និងថាមពលខេត្ត | សមាជិក |

**ប្រការ ២.**

ក្រុមការងារនេះមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ពិនិត្យតាមដាន ផ្អាក និងទប់ស្កាត់រាល់សកម្មភាពសាងសង់ស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈថ្មី ដែលពុំទាន់មានលិខិតបញ្ជាក់បច្ចេកទេសសុវត្ថិភាព នៃការបង្កើតស្ថានីយ ពីក្រសួងរ៉ែ និងថាមពល និងណែនាំឱ្យមកដាក់ពាក្យស្នើសុំលិខិតបញ្ជាក់បច្ចេកទេសសុវត្ថិភាព នៅមន្ទីររ៉ែ និងថាមពលខេត្ត ជាមុនសិន
- អប់រំណែនាំ និងផ្សព្វផ្សាយដល់ម្ចាស់ស្ថានីយប្រេង និងឧស្ម័នឥន្ធនៈទាំងអស់ ដែលកំពុងដំណើរការអាជីវកម្ម ដោយពុំទាន់មានការអនុញ្ញាតពីក្រសួងរ៉ែ និងថាមពល ឱ្យយល់ដឹងពីសារាចរ និង

ប្រកាសខាងលើ ដើម្បីជម្រុញម្ចាស់ស្ថានីយទាំងនោះ ឱ្យមកដាក់ពាក្យស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការស្ថានីយ នៅមន្ទីររ៉ែ និងថាមពលខេត្ត

- ចុះពិនិត្យ និងវាយតម្លៃ ចំពោះរាល់ស្ថានីយទាំងឡាយណា ដែលពុំមានលក្ខណៈបច្ចេកទេសត្រឹមត្រូវ និងតម្រូវឱ្យម្ចាស់ធ្វើការកែសម្រួលស្ថានីយរបស់ខ្លួន ស្របតាមសារាចរស្ដីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ
- មន្ទីររ៉ែ និងថាមពលខេត្ត រដ្ឋបាលក្រុង-ស្រុកគ្រប់ស្រុក និងទីចាត់ការអន្តរវិស័យសាលាខេត្តត្រូវសហការប្រមូល ចងក្រងទិន្នន័យ និងព័ត៌មានពីស្ថានីយប្រេង និងឧស្ម័នឥន្ធនៈ នៅតាមបណ្ដាក្រុង-ស្រុក ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង។

សមាជិកក្រុមការងារត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុម និងមានសិទ្ធិចាត់តាំងមន្ត្រីក្រោមឱវាទមន្ទីរ អង្គភាពរបស់ខ្លួនដើម្បីសហការ សម្របសម្រួលការងារនេះឲ្យមានប្រសិទ្ធភាពខ្ពស់។ រាល់ការចុះបំពេញភារកិច្ចនៅតាមបណ្ដាក្រុង-ស្រុក ត្រូវមានលិខិតបញ្ជាបេសកកម្មចេញដោយរដ្ឋបាលខេត្ត និងត្រូវធ្វើរបាយការណ៍ជាក់លាក់ស្ដីពីលទ្ធផលបេសកកម្ម ជូនប្រធានក្រុមការងារត្រួតពិនិត្យ។

**ប្រការ ៣.-**

នាយករដ្ឋបាលសាលាខេត្ត ប្រធានមន្ទីររ៉ែ និងថាមពលខេត្ត ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ប្រធានមន្ទីរបរិស្ថានខេត្ត ស្នងការនគរបាលខេត្ត មេបញ្ជាការកងរាជអាវុធហត្ថខេត្ត អភិបាលក្រុង-ស្រុកគ្រប់ស្រុក និងសាមីខ្លួនដែលមានឈ្មោះក្នុងប្រការ ១ ខាងលើ ត្រូវអនុវត្តសេចក្ដីសម្រេចនេះឲ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ៕

**អភិបាលខេត្ត**

**ឡាយ វណ្ណៈ**

**កន្លែងទទួល**

- ក្រសួងមហាផ្ទៃ
- ក្រសួងរ៉ែ និងថាមពល
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងបរិស្ថាន

  "ដើម្បីជូនជ្រាប"

- ដូចប្រការ៣

  "ដើម្បីអនុវត្ត"

- ឯកសារ.កាលប្បវត្តិ